ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 12 / 2011
ម៉ោង (Time/Heure): 12:03
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តារ** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង បន្ទាប់ពីមានការបញ្ចេញឯកសារសម្ងាត់នានាដោយគ្មានការអនុញ្ញាត

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Andrew IANUZZI
Victor KOPPE
អាង ឧត្តម

Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គជំនុំជម្រះ" និង "អ.វ.ត.ក")៖

**បានទទួល** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសជ អនុលោមតាមសាលដីកា ដែលបានចេញដោយអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយធ្វើឡើងដោយ អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន[១]។

**បានឃើញ** "សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម" ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ (E115/3) ("សេចក្តីសម្រេចលើសម្បទា") ដែលបានសង្កេតឃើញថា វេជ្ជបណ្ឌិត Bursztajn ដែលជាអ្នកពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រពីខាងក្រៅដែលបានផ្តល់របាយការណ៍ដល់មេធាវីការពារក្តី ត្រូវបានគេផ្តល់ឱ្យនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុតមួយចំនួន ដោយរំលោភលើមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង[២]។

**បានឃើញបន្ថែមទៀតថា** សេចក្តីសម្រេចលើសម្បទាបានណែនាំមេធាវីការពារក្តីឱ្យបញ្ជាក់ថាតើឯកសារដែលត្រូវបានចាត់ថ្នាក់រួចហើយ នៅតែកំពុងស្ថិតក្នុងដៃរបស់តតីយជន ឬយ៉ាងណា និងត្រូវ

---

[១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/4/14។ និងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំង នឹងដីកាដំណោះស្រាយដែលសម្រេចពន្យារចិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ន ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/5/9។

[២] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១១០ (ដែលបង្ហាញថា មេធាវីការពារក្តី "ក៏ចង់ធ្វើការវាយតម្លៃលើចម្លើយនានាដែលបានផ្តល់ឱ្យដោយសាស្ត្រាចារ្យ Campbell ដោយប្រើអ្នកជំនាញផ្នែកវេជ្ជសាស្ត្រផ្ទាល់របស់ពួកគេ")។ បន្ទាប់មក មេធាវីការពារក្តីបានដាក់សេចក្តីបន្ថែមលើ "សំណើសុំចាត់តាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃសម្បទារបស់លោក នួន ជា ក្នុងការចូលរួមសវនាការ" (ឯកសារ E115) នូវរបាយការណ៍មួយដែលបានមកពីវេជ្ជបណ្ឌិត Burztajn ដែលត្រូវបានបង្ហាញទៅចំពោះសមាជិកពីររូបនៃក្រុមមេធាវីការពារក្តី នួន ជា និងដែលត្រូវបានចុះក្នុងឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុតដែលបានយោងនៅក្នុងជើងទំព័រលេខ ៩២ នៃសេចក្តីសម្រេចលើសម្បទា (ឯកសារ E115.2.1)។

រាយការណ៍ជូនអង្គជំនុំជម្រះក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះ តទៅពាក់ព័ន្ធនឹងវិធានការនានាដែលនឹងអនុវត្តក្នុងការទប់ស្កាត់កុំឲ្យវេជ្ជបណ្ឌិត Bursztajn និងតតីយជនផ្សេងៗទៀត ចែកចាយ ឬបញ្ចេញឯកសារទាំងនេះទៀត ដោយគ្មានការអនុញ្ញាត[៣]។

**បានពិចារណាលើ** "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការចែកចាយដោយមិនមានការអនុញ្ញាតនូវឯកសារសម្ងាត់បំផុតទៅអ្នកពិគ្រោះយោបល់ខាងក្រៅ ដោយក្រុមមេធាវីការពារក្ដី លោក នួន ជា"។ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនេះត្រូវបានដាក់ដោយមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("មេធាវីការពារក្ដី") នៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ (E147) ("សំណើសុំ") ដោយបានកត់សម្គាល់ឃើញថា "អង្គជំនុំជម្រះហាក់ដូចជាគិតថា "មានហេតុផលជឿជាក់ថា សមាជិកម្នាក់ ឬច្រើនជាងនេះនៃមេធាវីការពារក្ដីអាចប្រព្រឹត្តអំពើមួយក្នុងចំណោមអំពើ ទាំងឡាយដែលមានចែងនៅក្នុងវិធាន ៣៥(១)"" និងបានស្នើសុំអង្គជំនុំជម្រះឲ្យដឹកនាំកិច្ចស៊ើបសួរបន្ថែម ដើម្បីបញ្ជាក់ថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្ដើមនីតិ-វិធីប្ដឹងអនុលោមតាមវិធាន ៣៥ នៃ វិធានផ្ទៃក្នុង ដែរឬទេ ជាពិសេសតាមរយៈការធ្វើសម្ភាសន៍មេធាវីការពារក្ដីនោះ។

**បានពិចារណាបន្ថែមទៀតថា** ផ្ទុយនឹងការអះអាងរបស់មេធាវីការពារក្ដី អង្គជំនុំជម្រះនៅក្នុងសេចក្ដីសម្រេចលើសម្បទាមិនបានដាក់ទណ្ឌកម្មជារួមលើមេធាវីការពារក្ដីអនុលោមតាមវិធាន ៣៥ ឬវិធាន ៣៨ នៃវិធានផ្ទៃក្នុងឡើយ ហើយក៏មិនបានផ្ដើមនីតិវិធីប្ដឹងអនុលោមតាមវិធានទាំងអស់នេះដែរ។ ប៉ុន្តែអង្គជំនុំជម្រះគ្រាន់តែបានព្រមានមេធាវីការពារក្ដីមិនឲ្យបញ្ចេញព័ត៌មានសម្ងាត់ និងសម្ងាត់បំផុតដោយគ្មានការអនុញ្ញាតតទៅទៀត អនុលោមតាមវិធាន ៣៥(៥) និងវិធាន ៣៨ នៃវិធានផ្ទៃក្នុង តែប៉ុណ្ណោះ។

**កត់សម្គាល់ឃើញថា** មេធាវីការពារក្ដីមិនបានរាយការណ៍ត្រឡប់ជូនអង្គជំនុំជម្រះវិញ ដូចដែលបានណែនាំតាមរយៈសេចក្ដីសម្រេចលើសម្បទាឡើយ ហើយក៏មិនបានទាក់ទងជាមួយវេជ្ជបណ្ឌិត Bursztajn ដើម្បីការពារ និងទប់ស្កាត់ការបញ្ចេញឯកសារទាំងអស់នេះថែមទៀតដែរ ដោយមេធាវី

[៣] សេចក្ដីសម្រេចលើសម្បទា ទំព័រ ១៧។

ការពារក្តីបានលើកឡើងជំនួសវិញថា សំណើសុំនេះ មានចម្លើយតបទាំងស្រុងទៅនឹងសេចក្តីណែនាំនានា ដែលមាននៅក្នុងសេចក្តីសម្រេចលើសម្បទាហើយ[៩]។

**កត់សម្គាល់ឃើញបន្ថែមទៀតថា** វិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវឆន្ទានុសិទ្ធិក្នុងការដោះស្រាយជារួមនូវបញ្ហានានាដែលពាក់ព័ន្ធនឹងការបញ្ចេញព័ត៌មានសម្ងាត់ដោយរំលោភលើដីកាបង្គាប់របស់អង្គជំនុំជម្រះ ឬបញ្ជូនករណីនេះទៅសមត្ថកិច្ចពាក់ព័ន្ធនៅពេលដែលអង្គជំនុំជម្រះមានហេតុផលដែលនាំឱ្យជឿបានថា បុគ្គលម្នាក់បានប្រព្រឹត្តផ្ទុយនឹងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង។

**យល់ឃើញថា** កាលៈទេសៈនានាខាងលើផ្តល់នូវសំអាងហេតុដើម្បីឱ្យអង្គជំនុំជម្រះជឿជាក់ថាមេធាវីការពារក្តីបានបញ្ចេញឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុតឱ្យទៅវេជ្ជបណ្ឌិត Bursztajn ដោយគ្មានការអនុញ្ញាត និងថាមេធាវីការពារក្តីបានខកខានថែមទៀតក្នុងការអនុវត្តឱ្យស្របតាមសេចក្តីណែនាំនានារបស់អង្គជំនុំជម្រះដើម្បីកម្រិតអំពីផលប៉ះពាល់នៃការបញ្ចេញឯកសារដោយគ្មានការអនុញ្ញាតនេះ។

## ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ÷

**រំលឹក** ភាគីនានាថា អនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អាចដាក់ទណ្ឌកម្ម ឬបញ្ជូនករណីនេះទៅសមត្ថកិច្ចពាក់ព័ន្ធដើម្បីចាត់វិធានការចំពោះជនណាដែលបញ្ចេញនូវព័ត៌មានសម្ងាត់ដោយបានដឹងជាមុន និងដោយចេតនា ដោយរំលោភទៅលើដីកាបង្គាប់របស់អង្គជំនុំជម្រះ។

**បង្គាប់** ការិយាល័យរដ្ឋបាលឱ្យផ្តល់ដំណឹងអំពីសេចក្តីសម្រេចនេះដល់វេជ្ជបណ្ឌិត Bursztajn និងបង្គាប់ឱ្យវេជ្ជបណ្ឌិត Bursztajn ផ្តល់ព័ត៌មានក្នុងរយៈពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់អង្គជំនុំជម្រះវិញ អំពីថាតើគាត់ទទួលបានឯកសារសម្ងាត់នានាដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចនេះតាមវិធីណា និងឱ្យបញ្ជាក់ថាតើគាត់នៅមានឯកសារទាំងនោះ ដែរ ឬ

[៩] សំណើសុំ កថាខណ្ឌ ៩។

ទេ និងឱ្យបញ្ជាក់ថែមទៀតថាតើមានឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះត្រូវបានបញ្ជូនបន្តទៅឱ្យបុគ្គលណាមួយផ្សេងទៀតដែរ ឬទេ។

**បង្គាប់** មិនឱ្យអង្គភាពបកប្រែភាសាធ្វើការបកប្រែសំណើសុំបំពេញកិច្ចស៊ើបសួរ (E147) ទៅជាភាសាខ្មែរ និងភាសាបារាំងទេ។

**បង្គាប់ថែមទៀត** ដល់ភាគីនានាមិនចាំបាច់ធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីឡើយ។

**បញ្ជូន** បញ្ហានេះទៅផ្នែកគាំពារការការពារក្ដីដើម្បីធ្វើការពិនិត្យមើលឡើងវិញ អនុលោមតាមអំណាចរបស់ផ្នែកនេះក្នុងការបដិសេធនូវការផ្ដល់ប្រាក់កម្រៃសម្រាប់ការងារ នៅពេលដែលការងារដែលត្រូវបានធ្វើឡើងនោះមិន "ចាំបាច់ និងមិនសមហេតុផល"។ អនុលោមតាមវិធាន ១១(២)(ជ) នៃវិធានផ្ទៃក្នុង ផ្នែកគាំពារការការពារក្ដីមានកាតព្វកិច្ច "ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ ជាមួយមេធាវីការពារក្ដី និងអនុញ្ញាតឱ្យផ្ដល់ប្រាក់កម្រៃសរុបទៅតាមលទ្ធផលការងារ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី"។

**ស្នើថា** ប្រាក់កម្រៃសម្រាប់មេធាវីការពារក្ដីទាក់ទងនឹងការរៀបចំសំណើសុំនេះ មិនត្រូវអនុញ្ញាតឱ្យផ្ដល់ឱ្យទៅមេធាវីទេ ដោយយោងតាមបទបញ្ញត្តិពាក់ព័ន្ធនឹងការផ្ដល់កម្រៃសេវាទាំងនេះ។

ភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន